ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៩៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងធានាការគ្រប់គ្រង និងការអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានប្រកបដោយតម្លាភាព អព្យាក្រឹត្យ និងមិនរើសអើង ដោយកំណត់អំពីៈ

- ការគ្រប់គ្រង ការប្រមូល និងការចាត់ចែងមូលនិធិការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពទាំងឡាយណា ដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យដូចតទៅៈ

១. **គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល ស្រាវជ្រាវនិងអភិវឌ្ឍ និងនវានុវត្តន៍** សំដៅដល់ស្ថាប័នទទួលបន្ទុកផ្តល់ការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ក្នុងវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលទទួលស្គាល់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន។

២. **ចំណូលដុល** សំដៅដល់ប្រាក់ចំណូលទាំងអស់របស់ប្រតិបត្តិករទូរគមនាគមន៍ ដែលបានមកពីប្រតិបត្តិការទូរគមនាគមន៍ ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍ ដោយមិនទាន់កាត់កងចំណាយណាទាំងអស់ លើកលែងតែចំណូលពីការលក់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍។

៣. **មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** សំដៅដល់សំណុំនៃថវិកាទាំងឡាយដែលប្រើប្រាស់ដើម្បីទ្រទ្រង់និងលើកកម្ពស់ដល់ការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន តទៅនេះហៅកាត់ថា "**មូលនិធិ ស.អ**"។

## ជំពូកទី២
## គណៈកម្មាធិការគ្រប់គ្រងមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា៤ .-**

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ដែលមានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ប្រធាន
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ២រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប អនុប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
- អគ្គនាយក នៃអគ្គនាយកដ្ឋានទូរគមនាគមន៍ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក
- អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក
- អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក។

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

**មាត្រា៥ .-**

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង និងចាត់ចែងមូលនិធិ ស.អ
- លើកកម្ពស់ និងជំរុញការអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ពិនិត្យ និងសម្រេចលើកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ពិនិត្យ និងសម្រេចលើផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ពិនិត្យ និងសម្រេចលើផែនការនិងយន្តការអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង
- ពិនិត្យ និងសម្រេចលើយន្តការទូទាត់គម្រោងអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

- រៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានជូនរាជរដ្ឋាភិបាល
- ផ្ដល់យោបល់ជូនរាជរដ្ឋាភិបាលអំពីវិភាគទានពីប្រតិបត្តិករទូរគមនាគមន៍ ដែលត្រូវចូលរួមក្នុងមូលនិធិ ស.អ
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នរដ្ឋ ឬឯកជន ឬដៃគូអភិវឌ្ឍន៍
- ពិនិត្យ និងសម្រេចលើការផ្ដល់ ការបន្ត ការផ្អាក ការផ្ទេរ ឬការបញ្ឈប់គម្រោងអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ពិនិត្យ និងសម្រេចលើថវិកាសម្រាប់គម្រោងអនុវត្តកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ពិនិត្យ និងសម្រេចលើថវិកាប្រចាំឆ្នាំរបស់មូលនិធិ ស.អ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់មូលនិធិ ស.អ ជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រមុខរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៦ .-**

អនុប្រធាន និងសមាជិកគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដឹកនាំការប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ជំនួសបាន។

**មាត្រា៧ .-**

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ អាចមានអ្នកជំនាញការជាតិ ឬអន្តរជាតិមួយចំនួនដែលមានសមត្ថភាព ជំនាញ និងបទពិសោធន៍ខ្ពស់ ដើម្បីជួយបម្រើការងារជាទីប្រឹក្សាបច្ចេកទេស។

**មាត្រា៨ .-**

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ មានសិទ្ធិប្រើត្រារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

**មាត្រា៩ .-**

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ មានអគ្គនាយកដ្ឋានបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាសេនាធិការផ្នែកបច្ចេកទេស និងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាសេនាធិការផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ។

តួនាទី និងភារកិច្ចរបស់សេនាធិការផ្នែកបច្ចេកទេស និងសេនាធិការផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

**មាត្រា១០ .-**

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ មានកញ្ចប់ថវិកាសម្រាប់ដំណើរការការងាររបស់ខ្លួន ដែលត្រូវដកចេញពីមូលនិធិ ស.អ ប្រចាំឆ្នាំយ៉ាងច្រើន ១០ (ដប់) ភាគរយ។

ការផ្ដល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តាមសំណើរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

ការផ្ដល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនមន្ត្រីដែលបម្រើការងារក្នុងសេនាធិការផ្នែកបច្ចេកទេស និងសេនាធិការផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ នៃគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ជំពូកទី៣
## មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

### ផ្នែកទី១
### ការប្រមូលនិងការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា១១ .-**

ប្រភពធនធាននៃមូលនិធិ ស.អ រួមមាន៖

- វិភាគទានប្រចាំឆ្នាំចំនួន ១ (មួយ) ភាគរយ នៃចំណូលដុលរបស់ប្រតិបត្តិករទូរគមនាគមន៍ ស្របតាមច្បាប់ស្ដីពីទូរគមនាគមន៍
- ធនធានដែលរដ្ឋ ឬក្រសួង ស្ថាប័ននានាផ្ដល់ឱ្យមូលនិធិ ស.អ សម្រាប់អនុវត្តគម្រោងរួមគ្នា
- ហិរញ្ញប្បទាន អំណោយ ថវិកាជំនួយ សម្ភារៈបរិក្ខារ ឧបករណ៍នានាពីសប្បុរសជន ដៃគូអភិវឌ្ឍន៍ ស្ថាប័នឯកជនជាតិ ឬអន្តរជាតិនានា
- ធនធានដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត។

ធនធាននៃមូលនិធិ ស.អ ត្រូវរក្សាទុកក្នុងគណនីរបស់មូលនិធិ ស.អ នៅធនាគារពាណិជ្ជណាមួយ ដោយមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២ .-**

ប្រតិបត្តិករទូរគមនាគមន៍ត្រូវបង់វិភាគទានចំនួន ១ (មួយ) ភាគរយ នៃចំណូលដុលឆ្នាំចាស់ទៅក្នុងគណនីមូលនិធិ ស.អ យ៉ាងយូរបំផុត ៩០ (កៅសិប) ថ្ងៃ ក្រោយការិយបរិច្ឆេទនៃឆ្នាំនីមួយៗ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលធ្វើសវនកម្មរួច មកគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

ក្នុងករណីមានលម្អៀងខ្វះនៃការគណនាទឹកប្រាក់បង់វិភាគទាន ប្រតិបត្តិករទូរគមនាគមន៍ត្រូវបង់បង្គ្រប់ក្នុងឆ្នាំដែលត្រូវបង់វិភាគទាន។ ក្នុងករណីមានលម្អៀងលើសនៃការគណនា ទឹកប្រាក់បង់វិភាគទានត្រូវរក្សាទុកក្នុងគណនីរបស់មូលនិធិ ស.អ សម្រាប់បង់នៅឆ្នាំបន្ទាប់។

ក្នុងករណីដែលប្រតិបត្តិករទូរគមនាគមន៍បង់វិភាគទានយឺតយ៉ាវលើសពីរយៈពេលដូចបានកំណត់ខាងលើ ប្រតិបត្តិករទូរគមនាគមន៍នោះត្រូវរងពិន័យជាប្រាក់ចំនួន ២ (ពីរ) ភាគរយ ក្នុងមួយខែ ដោយបូកយោងជា

បន្តបន្ទាប់តាមចំនួនខែដែលជំពាក់ តាមរូបមន្ត $X(1+r)^n$ ដែល X ជាបំណុលដើម r ជាអត្រាពិន័យក្នុងមួយខែ និង n ជាចំនួនខែ។

**មាត្រា១៣ .-**

កម្មវត្ថុនៃការប្រើប្រាស់មូលនិធិ ស.អ មានជាអាទិ៍ ដូចខាងក្រោម៖

ក. កសាងហេដ្ឋារចនាសម្ព័ន្ធ មជ្ឈមណ្ឌលនវានុវត្តន៍ មន្ទីរពិសោធន៍ ឬបន្ទប់ពិសោធន៍បម្រើឱ្យការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍ លើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ខ. អប់រំ និងបណ្តុះបណ្តាលលើជំនាញទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

គ. សិក្សា ស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ឃ.គាំទ្រដល់ការបង្កើតអាជីវកម្មនិងសេវាកម្មថ្មីៗលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ង. ផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតផ្នែកទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ច. បង្កើតព្រឹត្តិការណ៍ និងកម្មវិធីផ្សេងៗក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្ស និងធ្វើឱ្យកាន់តែប្រសើរឡើង នូវការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ឆ. បង្កើតកម្មវិធីប្រកួតប្រជែងទំនើបកម្មនៃបច្ចេកវិទ្យា និងភាពជាសហគ្រិនធ្វើមលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ជ. ចំណាយរដ្ឋបាលរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ និង

ឈ.កម្មវត្ថុផ្សេងៗទៀតដែលកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

**មាត្រា១៤ .-**

ប្រតិបត្តិករទូរគមនាគមន៍ដែលបានបង់វិភាគទានមូលនិធិ ស.អ មានសិទ្ធិស្នើសុំយ៉ាងច្រើនត្រឹម ២០ (ម្ភៃ) ភាគរយនៃមូលនិធិដែលខ្លួនបានបង់ ចំពោះគម្រោងជាអាទិ៍៖

- អប់រំ និងបណ្តុះបណ្តាលលើជំនាញទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតផ្នែកទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- បង្កើតព្រឹត្តិការណ៍ និងកម្មវិធីផ្សេងៗក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្ស និងធ្វើឱ្យកាន់តែប្រសើរឡើង នូវការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- បង្កើតកម្មវិធីប្រកួតប្រជែងទំនើបកម្មនៃបច្ចេកវិទ្យា និងភាពជាសហគ្រិនធ្វើមលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និង
- កម្មវត្ថុផ្សេងៗទៀតដែលកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ មានសិទ្ធិចាត់ចែងមូលនិធិ ស.អ ដែលនៅសេសសល់ក្នុងគោលដៅ ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ ហើយផលដែលកើតចេញពីការប្រើប្រាស់មូលនិធិនេះ

ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ក្រសួង ស្ថាប័ន ឬនីតិបុគ្គលដទៃទៀត អាចគ្រប់គ្រង និងចាត់ចែងផលពីគម្រោងនៃមូលនិធិ ស.អ បាន តាមការសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការប្រើប្រាស់មូលនិធិ ស.អ ត្រូវកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

**មាត្រា១៥ .-**

កញ្ចប់ថវិការបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវប្រើប្រាស់សម្រាប់មុខសញ្ញាចំណាយដូចខាងក្រោម៖

- ដំណើរការ និងការបំពេញភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ សេនាធិការផ្នែកបច្ចេកទេស និងសេនាធិការផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ
- ឧបត្ថម្ភសម្រាប់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ
- ឧបត្ថម្ភសម្រាប់ប្រធាន អនុប្រធាន ទីប្រឹក្សាបច្ចេកទេស មន្ត្រីរាជការ និងបុគ្គលិកនៃសេនាធិការផ្នែកបច្ចេកទេស និងសេនាធិការផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ
- ការទិញ ការជួល ការជួសជុល ឬការថែទាំយានជំនិះ សង្ហារិម សម្ភារៈការិយាល័យ
- ចំណាយលើប្រេងឥន្ធនៈ ប្រេងរំអិល
- ចំណាយជាក់ស្តែងផ្សេងៗទៀតតាមការចាំបាច់របស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

## ផ្នែកទី២
## លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំ ការផ្តល់ និងការទូទាត់ គម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា១៦ .-**

បុគ្គលដែលមានសិទ្ធិស្នើសុំមូលនិធិ ស.អ មានដូចខាងក្រោម៖

- ប្រតិបត្តិករទូរគមនាគមន៍ដែលបានបំពេញប្រតិបត្តិការ ដូចមានចែងក្នុងមាត្រា១៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ និងបានអនុវត្តកាតព្វកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន
- គ្រឹះស្ថានសាធារណៈ ដែលផ្តល់ការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវនិងការអភិវឌ្ឍនិងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- បុគ្គលផ្សេងទៀតដែលមានគុណវុឌ្ឍិឆ្លើយតបទៅនឹងកម្មវត្ថុណាមួយ ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ។

**មាត្រា១៧ .-**

បុគ្គលដែលអាចទទួលបានមូលនិធិ ស.អ ត្រូវបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- បានអនុវត្តកាតព្វកិច្ចបង់វិភាគទានចូលមូលនិធិ ស.អ ស្របតាមអនុក្រឹត្យនេះនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ចំពោះបុគ្គលស្នើសុំជាប្រតិបត្តិករទូរគមនាគមន៍



ថ្ងៃ

- ពុំមានជាប់បំណុលដោយការខកខានបង់វិភាគទានចូលមូលនិធិ ស.អ ឬខកខានបង់ចំណូលពីប្រតិបត្តិការផ្សេងៗដែលកំណត់ដោយច្បាប់ស្តីពីទូរគមនាគមន៍ ចំពោះបុគ្គលស្នើសុំជាប្រតិបត្តិករទូរគមនាគមន៍
- មានសក្តានុពលភាពផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងមានធន្ទះក្នុងការសម្រេចនូវគម្រោងកម្មវិធីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

**មាត្រា១៨ .-**

បុគ្គលដែលស្នើសុំមូលនិធិ ស.អ ត្រូវដាក់ពាក្យស្នើសុំទៅគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ យ៉ាងយូរត្រឹមដំណាច់ខែមករានៃឆ្នាំនីមួយៗ ដោយភ្ជាប់មកជាមួយនូវគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីពិនិត្យ និងសម្រេច។

ក្នុងករណីដែលគម្រោងត្រូវបានជ្រើសរើស បុគ្គលដែលស្នើសុំមូលនិធិ ស.អ ត្រូវធ្វើការសិក្សា និងផ្តល់របាយការណ៍សមិទ្ធិលទ្ធភាពជូនគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ដោយភ្ជាប់មកជាមួយនូវឯកសារគម្រោងបច្ចេកទេស និងហិរញ្ញវត្ថុ និងផែនការសកម្មភាព។

លក្ខខណ្ឌ បែបបទ និងនីតិវិធីលម្អិត នៃការសម្រេច ត្រូវកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

បុគ្គលដែលស្នើសុំមូលនិធិ ស.អ អាចប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អទៅតុលាការក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។

រាល់គម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលត្រូវបានសម្រេចដោយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ត្រូវផ្សព្វផ្សាយជាសាធារណៈ។

**មាត្រា១៩ .-**

ការផ្តល់ថវិកាដល់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ ត្រូវធ្វើឡើងតាមរយៈការផ្ទេរវាងគណនីធនាគារ ក្រោយពេលដែលគម្រោងទទួលបានការសម្រេចពីគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

បែបបទ និងនីតិវិធីនៃការផ្តល់ថវិកានេះ អាចត្រូវបានកំណត់បន្ថែមដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

## ផ្នែកទី៣

## ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃ
## ការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ
## លើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា២០ .-**

ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ ត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានជូនគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ ត្រូវបង្កភាពងាយស្រួល និងសហការជាមួយគណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ក្នុងការចុះត្រួតពិនិត្យនិងតាមដានការអនុវត្តគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងឆ្លើយតបទៅនឹងបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោង។

ក្នុងករណីដែលគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានណាមួយមិនដំណើរការ ឬដំណើរការពុំស្របតាមផែនការសកម្មភាព គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ អាចចាត់វិធានការបន្ទាន់ ដើម្បីផ្អាក ឬបញ្ឈប់ការអនុវត្តគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងដាក់ទណ្ឌកម្មដូចមានចែងជំពូកទី៤ នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## ទណ្ឌកម្ម

**មាត្រា២១ .-**

ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍មិនបង់វិភាគទានកាតព្វកិច្ចនៃមូលនិធិ ស.អ គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ អាចស្នើសុំទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីចាត់វិធានការជាអាទិ៍ ដូចខាងក្រោម៖

ក. បង្អាកការនាំចេញ និង/ឬ ការនាំចូលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

ខ. បង្អាកគណនីរបស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ ដើម្បីអនុវត្តគម្រោងអនុវត្តកម្មវិធីនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

គ. ដាក់កំហិតលើអាជ្ញាបណ្ណ

ឃ. ព្យួរអាជ្ញាបណ្ណ

ង. ព្យួរបណ្ដោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយកប្រតិបត្តិ សមាជិកគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់ របស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ

ច. ជ្រើសរើស និងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ច ដើម្បីពិនិត្យសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ

ឆ. ចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ស្របតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**មាត្រា២២ .-**

ដោយពុំទាន់រាប់បញ្ចូលទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងទណ្ឌកម្មព្រហ្មទណ្ឌ ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ ស.អ ដែលមិនអនុវត្តតាមគម្រោង អនុវត្តគម្រោងមិនបានត្រឹមត្រូវ ប្រើប្រាស់មូលនិធិមិនសមស្រប តាមរយៈការលួចកិបកេង ក្លែងបន្លំ ឬប្រើប្រាស់ខុសគោលដៅ ជាអាទិ៍ ត្រូវបង្វិលទឹកប្រាក់ដែលបានទទួល បូករួមទាំងការប្រាក់ដូចមានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ គិតចាប់ពីថ្ងៃ

ដែលរកឃើញថាបានប្រព្រឹត្តល្មើស មកគណនីរបស់មូលនិធិ ស.អ វិញ។ ការបង្វិលប្រាក់ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ។

**មាត្រា២៣ .-**

ក្នុងករណីដែលប្រតិបត្តិករទូរគមនាគមន៍ មិនអនុវត្តតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ដូចមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ គណៈកម្មាធិការអាចសម្រេចចាត់វិធានការលើប្រតិបត្តិករទូរគមនាគមន៍នោះតាមជម្រើសណាមួយ ដូចមានចែងក្នុងមាត្រា២១ នៃអនុក្រឹត្យនេះ។

ក្នុងករណីបុគ្គលដែលទទួលបានមូលនិធិ ស.អ មិនអនុវត្តតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ដូចមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ គណៈកម្មាធិការអាចសម្រេចចាត់វិធានការដូចខាងក្រោម៖

- មិនអនុញ្ញាតឱ្យចូលរួមស្នើសុំមូលនិធិ ស.អ នាពេលអនាគត
- ផ្សព្វផ្សាយជាសាធារណៈតាមបណ្តាញសារព័ត៌មាន ឬគេហទំព័រ
- ប្តឹងទៅតុលាការមានសមត្ថកិច្ច។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា២៤ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយ ដែលពាក់ព័ន្ធនឹងការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា២៥ .-**

អនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន អនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា៥ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ